ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សេចក្តីជូនដំណឹង
## ស្តីពីការចាក់វ៉ាក់សាំងកូវីដ-១៩
## ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ក្នុងក្របខណ្ឌថ្នាក់ជាតិនៃក្រសួងមុខងារសាធារណៈ

ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងថា ការចាក់វ៉ាក់សាំងជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់របស់ក្រសួងមុខងារសាធារណៈ នឹងប្រព្រឹត្តទៅនៅថ្ងៃទី**១** ខែ**មេសា** ឆ្នាំ**២០២១** និងព្រឹកថ្ងៃទី**២** ខែ**មេសា** ឆ្នាំ**២០២១** នៅ**សាលាភូមិន្ទរដ្ឋបាល** ចាប់ពីម៉ោង**៧.០០**នាទីព្រឹកតទៅ។

ដើម្បីធានាឱ្យដំណើរការនៃការចាក់វ៉ាក់សាំងនេះបានប្រព្រឹត្តទៅដោយរលូន និងគោរពតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ក្រសួងមុខងារសាធារណៈ សូមធ្វើការណែនាំដូចខាងក្រោម៖

ទី១. កាលវិភាគនៃការចាក់វ៉ាក់សាំងកូវីដ-១៩

| ល.រ. | ឈ្មោះអង្គភាព | កាលបរិច្ឆេទ | វេន | ម៉ោង |
|---|---|---|---|---|
| ១ | ថ្នាក់ដឹកនាំក្រសួងជា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ | ១ មេសា ២០២១ | ព្រឹក | ៧:០០-៨:៣០ |
| ២ | សាលាភូមិន្ទរដ្ឋបាល | | ព្រឹក | |
| ៣ | អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | | ព្រឹក | ៨:៣០-១១:០០ |
| ៤ | អង្គភាពលទ្ធកម្ម | | ព្រឹក | |
| ៥ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | | រសៀល | ១:០០-២:៣០ |
| ៦ | អគ្គាធិការដ្ឋាន | | រសៀល | |
| ៧ | អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ | | រសៀល | ២:៣០-៥:០០ |
| ៨ | ខុទ្ទកាល័យ និងទីប្រឹក្សា | ២ មេសា ២០២១ | ព្រឹក | ៧:០០-៨:៣០ |
| ៩ | អគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ | | ព្រឹក | ៨:៣០-១១:០០ |

ទី២. ត្រូវយកទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចុះឈ្មោះចាក់វ៉ាក់សាំងតាមប្រព័ន្ធអនឡាញជាមុន និងពាក់អាវដៃខ្លីនៅពេលចាក់វ៉ាក់សាំង។

ទី៣. ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ បញ្ជូនជំនួយការ និងមន្ត្រីជាប់កិច្ចសន្យាក្រោមឱវាទឱ្យចូលរួមចាក់វ៉ាក់សាំងជាមួយនឹងកម្មវិធីរបស់អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ។

ទី៤. អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន សាលាភូមិន្ទរដ្ឋបាល និងអង្គភាពផ្សេងទៀតត្រូវចាត់តំណាងដើម្បីត្រួតពិនិត្យ សម្របសម្រួល និងរៀបចំរបាយការណ៍លទ្ធផលនៃការចាក់វ៉ាក់សាំងក្នុងទម្រង់ដែលបានជូន រួចផ្តល់ទៅ លោក **ម៉េង ម៉ង់ទិត** យ៉ាងយូរត្រឹមមួយម៉ោងក្រោយពីការចាក់វ៉ាក់សាំងរបស់អង្គភាពនីមួយៗរួចរាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាទាំងអស់អនុវត្តតាមការជូនដំណឹងខាងលើឲ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh